**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការក្រុងព្រះសីហនុ
<u>សំណុំរឿងព្រហ្មទណ្ឌ</u>
លេខ ៤៥ ចុះថ្ងៃទី ១០
ខែ មីនា ឆ្នាំ ២០០៤

<u>សាលក្រម</u>
លេខ ៣៧ ចុះថ្ងៃទី ០២
ខែ មិថុនា ឆ្នាំ ២០០៤

## **តាងនាមប្រជារាស្ត្រខ្មែរ**
## **តុលាការក្រុងព្រះសីហនុ**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ បានបើកសវនាការជាសាធារណៈ នៅតុលាការក្រុងព្រះសីហនុ នាថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០៤ ដោយមានសមាសភាពដូចតទៅនេះ :

**<u>ចៅក្រមជំនុំជំរះ</u>**

លោក [redacted] អនុប្រធានតុលាការក្រុងព្រះសីហនុ

**<u>តំណាងអយ្យការ</u>**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការក្រុងព្រះសីហនុ

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted]

សាលក្រមនេះបានចូលជាស្ថាពរហើយ ។
ក្រុងព្រះសីហនុ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤
ក្រឡាបញ្ជី [redacted]

ដើម្បីជំនុំជំរះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៤៥ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៤ ដែលមានជនជាប់ចោទឈ្មោះ **ឃ ចន** ភេទប្រុស អាយុ ៥០ឆ្នាំ ជាតិខ្មែរ កើតនៅស្រុកបាភ្នំ ខេត្តព្រៃវែង ទីលំនៅសព្វថ្ងៃក្រុមទី ១៥ ភូមិ ៣ សង្កាត់ ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ របររកស៊ី បើករថយន្តឈ្នួល ។ ប្រពន្ធឈ្មោះ **អ ម** មានកូន ០៣នាក់ ឪពុកឈ្មោះ **ឃ ស** (ស) ម្តាយឈ្មោះ **អ យ** (រ) ទោសពីមុន *គ្មាន* រត់គេចខ្លួន ។

ត្រូវចោទពីបទ "<u>បង្ករបួសស្នាមដោយចេតនា</u>" ប្រព្រឹត្តនៅភូមិ ៣ សង្កាត់ ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-បានឃើញដីកាសន្និដ្ឋានចោទប្រកាន់ជូនរឿងទៅជំនុំជំរះផ្ទាល់លេខ ១៥៦ ដ.ជ.រ ០៤ ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៤ របស់ព្រះរាជអាជ្ញាអមតុលាការក្រុងព្រះសីហនុ ។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ ៤១៦ ត.ព ០៤ ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៤ របស់ប្រធានតុលាការក្រុងព្រះសីហនុ ។

### **<u>ដំណើររឿងមានដូចតទៅ</u> :**

កាលពីថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៤ ឈ្មោះ **ឃ ចន** បានវាយកូនចុងរបស់ខ្លួនឈ្មោះ **ឃ សគន** ស្រាប់តែពេលនោះឈ្មោះ **អ ម** ដែលជាប្រពន្ធឈ្មោះ **ឃ ចន** បានស្រែកអោយប្តីបើកទ្វារកុំអោយវាយកូនមិនដឹងហេតុផល ពេលនោះឈ្មោះ **ឃ ចន**

CamScanner

បើកទ្វារ ព្រមទាំងយកខ្សែក្រវ៉ាត់វាយទៅលើប្រពន្ធរបស់ខ្លួនថែមទៀត បណ្ដាលអោយបែកក្បាល បន្ទាប់មកឈ្មោះ **ឃ ចន** ក៏បើកឡានចេញបាត់ទៅ ។

**នាពេលសវនាការ**

-តាមការអានចម្លើយរបស់ឈ្មោះ **ឃ ចន** ជាជនជាប់ចោទឆ្លើយថា : កាលពីថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៤ ខ្លួនពិតជាបានវាយកូនឈ្មោះ **ឃ សគន** ដោយហេតុវាទៅរៀន និង មកវិញដើរហួសពេល ។ ពេលដែលខ្លួនកំពុងវាយកូនប្រពន្ធខ្លួនមកដល់ ក៏កូនខ្លួនរត់ទៅខាងក្រោយម៉ែវា ខ្លួនក៏វាយ ២ខ្សែក្រវ៉ាត់ ក៏ត្រូវក្បាលម៉ែវាចេញឈាម ហើយខ្លួនរុញប្រពន្ធចេញ ហើយបើកឡានចេញទៅ ។

-ឈ្មោះ **អ ម** ជាដើមបណ្ដឹងរដ្ឋប្បវេណី និង ជាជនរងគ្រោះបានឆ្លើយថា : ឈ្មោះ **ឃ ចន** គឺជាប្ដីតែមិនបានរៀបការទេ ។ កាលពីថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៤ វេលាម៉ោង ១១:០០ថ្ងៃត្រង់ ក្នុងខណៈខ្លួននៅផ្សារ ឯកូនត្រឡប់មកពីរៀនវិញ ប្ដីរបស់ខ្លួនក៏វាយកូន ពេលនោះខ្លួនមកទាន់ឮសួរជេរកូនស្រី ខ្លួនក៏ឃាត់កុំអោយជេរវា ព្រោះវាធំហើយ កុំអោយវាមានអារម្មណ៍មិនល្អ ស្រាប់តែឈ្មោះ **ឃ ចន** ស្ទុះមកវាយខ្លួន ២ ខ្សែក្រវ៉ាត់បណ្ដាលអោយបែកក្បាល បន្ទាប់មកគាត់បានចាក់សោមិនអោយខ្លួន និង កូនចូលផ្ទះអស់មួយអាទិត្យ ហើយគាត់ក៏បើកឡានគេចខ្លួនរហូតមកដល់សព្វថ្ងៃនេះ ។ ចំពោះរឿងនេះ ខ្លួនសុំអោយតុលាការធ្វើការផ្ដន្ទាទោសឈ្មោះ **ឃ ចន** តាមច្បាប់ ។ ឯសំណងជម្ងឺចិត្ត ខ្លួនមិនទាមទារអ្វីទេ ។

-តាមការអានចម្លើយរបស់ឈ្មោះ **ឃ សគន** ជាសាក្សីឆ្លើយថា : កាលពីថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៤ ពេលខ្លួនត្រឡប់មកពីរៀនវិញ ប៉ាខ្លួនឈ្មោះ **ឃ ចន** ហៅខ្លួនអោយចូលក្នុងផ្ទះ ហើយគាត់បិទទ្វាររួចយកខ្សែក្រវ៉ាត់វាយខ្លួនតែម្ដង ដោយមិនបានសួរនាំអ្វីឡើយ ។ ពេលនោះម្ដាយខ្លួនមកដល់ គាត់ក៏ឃាត់ថាឈប់ជេរកូនទៅថ្ងៃស្អែកវាទៅប្រឡងផង ស្រាប់តែឈ្មោះ **ឃ ចន** បើកទ្វារហើយយកខ្សែក្រវ៉ាត់វាយម្ដាយខ្លួនចំនួន ២ខ្សែក្រវ៉ាត់បណ្ដាលអោយបែកក្បាលចេញឈាមរួចមកប៉ាខ្លួនទាញសក់ម្ដាយខ្លួនបោកផ្ទប់ទៅនឹងអណ្ដូងទឹក តែត្រូវបានគេឃាត់ ។ ក្រោយពេលកើតហេតុខ្លួនបាននាំម្ដាយទៅព្យាបាលនៅមន្ទីរពេទ្យអស់មួយថ្ងៃមួយយប់ ។

-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា : មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ **ឃ ចន** ពីបទបង្ករបួសស្នាមដោយចេតនា ប្រព្រឹត្តនៅភូមិ ៣ សង្កាត់ ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្ដន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ក្រោយពីបានស្ដាប់ការអានចម្លើយជនជាប់ចោទ

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនរងគ្រោះ

-ក្រោយពីបានស្ដាប់ការអានចម្លើយសាក្សី

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

**តុលាការក្រុងព្រះសីហនុ**

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**យល់ឃើញថា**

-កាលពីថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៤ វេលាម៉ោង ១១:០០ថ្ងៃត្រង់ ពិតជាមានករណី បង្ករបួសស្នាមនៅភូមិ ៣ សង្កាត់ ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ប្រាកដមែន ដែលបង្កឡើងដោយឈ្មោះ **ឃ ចន** បានវាយកូន

CamScanner

និងប្រពន្ធបណ្តាលអោយបែកក្បាលប្រពន្ធ ក្រោយពេលប្រព្រឹត្តបទល្មើសរួចឈ្មោះ **ចា ចន** ក៏រត់គេចខ្លួនរហូតដល់សព្វថ្ងៃ ។

-តាមការអានចម្លើយរបស់ជនជាប់ចោទឈ្មោះ **ចា ចន** បានបញ្ជាក់ថា : ខ្លួនពិតជាបានបង្ករបួសទៅលើឈ្មោះ **អ ម** ជាប្រពន្ធរបស់ខ្លួនប្រាកដមែន ។

-តាមចម្លើយសាក្សីឈ្មោះ **ចា សុគន** នៅពេលកើតហេតុខ្លួនបានឃើញឳពុកខ្លួនឈ្មោះ **ចា ចន** យកខ្សែក្រវាត់វាយទៅលើម្តាយខ្លួន បណ្តាលអោយបែកក្បាលចេញឈាម កាលពីថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៤ ប្រាកដមែន ។

-ជនជាប់ចោទឈ្មោះ **ចា ចន** មានកម្លាំងបរិបូរណ៍ និង មានស្មារតីគ្រប់គ្រាន់ប្រព្រឹត្តបទល្មើស ដោយដឹងខុសត្រូវ អំពើល្មើសរបស់ជនជាប់ចោទបំពានទៅលើមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ហើយក៏បានធ្វើអោយប៉ះពាល់ដល់សុខភាពរបស់ប្រពន្ធខ្លួនទៀតផង ។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ **ចា ចន** ពីបទបង្ករបួសស្នាមដោយចេតនា ប្រព្រឹត្តនៅភូមិ ៣ សង្កាត់ ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៤ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **អ ម** បានប្តឹងសុំអោយតុលាការធ្វើការផ្តន្ទាទោសឈ្មោះ **ចា ចន** ដែលជាប្តីទៅតាមច្បាប់ បណ្តឹងនេះមានលក្ខណៈសមស្របតាមច្បាប់ ។

**ហេតុដូច្នេះតុលាការក្រុងព្រះសីហនុ**

**សំរេច :**

**ផ្តន្ទាទោស :**

ផ្តន្ទាទោសឈ្មោះ **ចា ចន** ភេទប្រុស អាយុ ៥០ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០៣ខែ ( បីខែ ) គិតពីថ្ងៃនេះតទៅ ។

ពីបទបង្ករបួសស្នាមដោយចេតនា ប្រព្រឹត្តនៅភូមិ ៣ សង្កាត់ ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈកំបាំងមុខជនជាប់ចោទ ចំពោះមុខជនរងគ្រោះ បើកផ្លូវប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ក្រឡាបញ្ជី** [redacted]

**ចៅក្រមជំនុំជំរះ** [redacted]